BMI0099

# សម្ភាសន៍ជាមួយឈ្មោះ អៀម សួង ភេទប្រុស អាយុ៥៧ឆ្នាំ
## មុខងារជំនាន់ខ្មែរក្រហម“កងចល័ត”
## រស់នៅភូមិយាងវៀន ឃុំផ្គាំ ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ
## ថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០១០
## សម្ភាសន៍ដោយៈ សុខ វណ្ណៈ
## ០០:៣២:១៣
## ១២ទំព័រ

សុខ វណ្ណៈ ចឹងជាដំបូងខ្ញុំសូមប្រាប់ឈ្មោះខ្ញុំថា ខ្ញុំឈ្មោះសុខ វណ្ណៈ ។

អៀម សួងៈ បាទ ។

សុខ វណ្ណៈ មកពីមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលមានទីតាំងនៅភ្នំពេញ ខ្ញុំមកនេះគឺចង់រៀងរ៉ាវនៅស្រុកស្វាយចេក ខ្ញុំចង់ដឹងថាប្រជាជននៅហ្នឹងនៅពេលសង្គ្រាមមានជួបគ្រោះថ្នាក់វាមានបញ្ហាអីកើតឡើងខ្លះ តើវេទនាយ៉ាងម៉េច ហើយឥឡូវប្រជាជនផុតពីសង្គ្រាមហើយតើការរកស៊ីបង្កបង្កើនផលយ៉ាងម៉េចខ្លះ?

អៀម សួងៈ បាទ ។

សុខ វណ្ណៈ ចឹងបទសម្ភាសន៍ខ្ញុំជាមួយពូហ្នឹង តើពូអនុញ្ញាតឲ្យខ្ញុំយកទៅប្រើប្រាស់បានទេ?

អៀម សួងៈ បាន ។

សុខ វណ្ណៈ ចឹងពូអនុញ្ញាត?

អៀម សួងៈ បាទ ។

សុខ វណ្ណៈ ចឹងខ្ញុំចង់ស្គាល់ឈ្មោះពូ តើពូឈ្មោះអីដែរ?

អៀម សួងៈ ខ្ញុំឈ្មោះ អៀម សួង ។

សុខ វណ្ណៈ អាយុប៉ុន្មាន?

អៀម សួងៈ អាយុ៥៧ឆ្នាំ ។

សុខ វណ្ណៈ ប្រពន្ធឈ្មោះអី?

អៀម សួងៈ ប្រពន្ធដើមឈ្មោះ វឿន រ៉ាញ ។

សុខ វណ្ណៈ គាត់មានអាយុប៉ុន្មាន?

អៀម សួងៈ កាលដែលគាត់ស្លាប់អាយុ៣៨ ។

សុខ វណ្ណៈ   មានកូនប៉ុន្មាននាក់?

អៀម សួងៈ មានកូន៥នាក់ ។

សុខ វណ្ណៈ   ស្រីប៉ុន្មាន?

អៀម សួងៈ ស្រីទាំង៥នាក់ ។

សុខ វណ្ណៈ   ចឹងឪពុកពូឈ្មោះអី?

អៀម សួងៈ ឈ្មោះ អៀម ដាំង ។

សុខ វណ្ណៈ   គាត់ជនជាតិទេ បានជាឈ្មោះចឹង?

អៀម សួងៈ ទេ គាត់ជាជនជាតិខ្មែរហ្នឹង ។

សុខ វណ្ណៈ   ម្ដាយឈ្មោះ?

អៀម សួងៈ ឈ្មោះ ចយ កុំ ។

សុខ វណ្ណៈ   ចឹងគាត់ទាំងពីរសព្វថ្ងៃនៅរស់ដែរ?

អៀម សួងៈ នៅតែម្ដាយទេ ។

សុខ វណ្ណៈ   ពូមានបងប្អូនបង្កើតប៉ុន្មាននាក់?

អៀម សួងៈ បងប្អូនបង្កើតមាន៧នាក់ ។

សុខ វណ្ណៈ   ស្រីប៉ុន្មាន?

អៀម សួងៈ ស្រី៣ប្រុស៤ ។

សុខ វណ្ណៈ   ចឹងសព្វថ្ងៃនៅរស់ទាំងអស់?

អៀម សួងៈ បាទ!នៅរស់ទាំងអស់ ។

សុខ វណ្ណៈ   ចឹងស្រុកកំណើតនៅណា?

អៀម សួងៈ ស្រុកកំណើតនេះឯង ។

សុខ វណ្ណៈ   គេហៅភូមិអី?

អៀម សួងៈ ភូមិយាងវៀន ។

សុខ វណ្ណៈ   ឃុំ?

អៀម សួងៈ ផ្កាំ ។

សុខ វណ្ណៈ   ចឹងកាលពីដើមគេហៅស្រុកអីគេ?

អៀម សួងៈ កាលពីដើមគេហៅស្រុកថ្មពួក ។

សុខ វណ្ណៈ   កាលហ្នឹងគេហៅខេត្តអីគេ?

អៀម សួន៖ ខេត្តបាត់ដំបង ។

សុខ វណ្ណៈ ចឹងឥឡូវនៅភូមិឃាងវៀនដដែល?

អៀម សួន៖ បាទ ។

សុខ វណ្ណៈ ចឹងឥឡូវគេហៅស្រុកស្វាយចេកវិញហើយ?

អៀម សួន៖ បាទ ។

សុខ វណ្ណៈ ចឹងដូឈ្មោះតាំងពីពេលណា?

អៀម សួន៖ ដូយូរគ្រាន់ហើយខ្ញុំមិនបានចាំទេ ដូរកាលមានសន្តិភាព ។

សុខ វណ្ណៈ ចឹងកាលហ្នឹងរៀនបានដល់ថ្នាក់ណា?

អៀម សួន៖ កាលហ្នឹងរៀនបានថ្នាក់ទី១២«ចាស» ។

សុខ វណ្ណៈ ចឹងរៀនបានតែមួយឆ្នាំស្មើថ្នាក់ទី១ ឥឡូវ?

អៀម សួន៖ បាទ ។

សុខ វណ្ណៈ ចឹងឈប់រៀនហើយទៅណា?

អៀម សួន៖ ឈប់រៀនហើយបួសវិញ បួសបាននៅរៀននេះ ។

សុខ វណ្ណៈ រៀននៅសាលាណា?

អៀម សួន៖ សាលាផ្គាំនេះ ។

សុខ វណ្ណៈ បួសនៅវត្តណា?

អៀម សួន៖ វត្តផ្គាំហ្នឹង ។

សុខ វណ្ណៈ បួសនៅវត្តផ្គាំបានប៉ុន្មានឆ្នាំបានឈប់បួស?

អៀម សួន៖ បួសបានបីឆ្នាំ ។

សុខ វណ្ណៈ ឈប់នៅឆ្នាំណា?

អៀម សួន៖ មិនដឹងជាឆ្នាំណាម៉េចចាំ ។

សុខ វណ្ណៈ ចឹងនៅឆ្នាំ៧០មានរដ្ឋប្រហារដំនាន់សីហនុ ដល់៧១-៧២-៧៣ហ្នឹង ពូនៅបួសឬមួយសឹក ហើយ?

អៀម សួន៖ ខ្ញុំសឹកសម័យខ្មែរក្រហមចូលនោះបានខ្ញុំសឹក ។

សុខ វណ្ណៈ ៧៥?

អៀម សួន៖ កាលហ្នឹង៧៤ ។

សុខ វណ្ណៈ ចឹងពូសឹកហើយពូនៅធ្វើអីទៀត?

អៀម សួនៈ សឹកហើយមានធ្វើអីទេ ខ្ញុំធ្វើតែប្រជាជន សម័យធ្វើស្រែរួម ។

សុខ វណ្ណៈ ចឹងកាលខ្មែរក្រហមចូលមកនៅឆ្នាំ៧៥ ប្រជាជននៅហ្នឹងដូចជាពូអីទៅធ្វើអីនៅណា?

អៀម សួនៈ ខ្ញុំអត់មានធ្វើអីទេ ខ្ញុំធ្វើនៅតែទីនេះហើយធ្វើប្រជាជន ។

សុខ វណ្ណៈ ចឹងពូទៅធ្វើកងចល័ត?

អៀម សួនៈ បាទៗ!ទៅធ្វើកងចល័តខាងពង្រៀបដែកនៅត្រពាំងថ្ម ។

សុខ វណ្ណៈ ចឹងកាលហ្នឹងពូនៅជាយុវជនទេ?

អៀម សួនៈ កាលនោះខ្ញុំបានប្រពន្ធហើយ បានកាលនោះបានសម័យចាប់អារម្មណ៍ ។

សុខ វណ្ណៈ កាលហ្នឹងនៅឆ្នាំណា?

អៀម សួនៈ ឆ្នាំ៧៥ហ្នឹងឯង ទេមិនដឹងជាឆ្នាំណាទេ ចាំមិនបានទេ កាលនោះធ្វើការនៅត្រពាំងថ្ម គេហៅចាប់អារម្មណ៍ចាប់ដៃគ្នា ។

សុខ វណ្ណៈ ចឹងពូធ្វើការនៅត្រពាំងថ្មរហូតឬមួយយ៉ាងម៉េច?

អៀម សួនៈ អត់ទេ គេឲ្យទៅចប់ស្រែទៅគេឲ្យឡើងមកវិញ ដល់ចឹងទៅដើរភ្ជួរស្រែតាមភូមិនេះទៀតទៅ កាលនោះគេឲ្យទៅពង្រៀបដី ។

សុខ វណ្ណៈ ចឹងកាលហ្នឹងគេឲ្យទៅលើទំនប់អី?

អៀម សួនៈ បាទ! ។

សុខ វណ្ណៈ កាលលើទំនប់ចឹងមានឃើញយុវជនយុវនារីទៅដែរ?

អៀម សួនៈ ទេ កងយុវជនកងយុវនារីគេខាងលើកទំនប់ ខ្ញុំបានប្រពន្ធហើយចេះ គេឲ្យនៅខាងពង្រៀបដីខាងស្ទូង ។

សុខ វណ្ណៈ ចឹងការពូចាប់ដៃគ្នាហ្នឹងមានបាយរួមនៅ?

អៀម សួនៈ បាយរួមហើយ ។

សុខ វណ្ណៈ បាយរួមបានប្រហែលប៉ុន្មានឆ្នាំ?

អៀម សួនៈ បាយរួមប្រហែលមួយឆ្នាំ ។

សុខ វណ្ណៈ ចឹងកាលហ្នឹងប្រហែលជាឆ្នាំ៧៦?

អៀម សួនៈ បាទ ។

សុខ វណ្ណៈ ចឹងប្រពន្ធកាលហ្នឹងពូពេញចិត្តខ្លួនឯងឬមួយយ៉ាងម៉េច?

អៀម សួនៈ បាទ!ពេកចិត្តខ្លួនឯង ។

សុខ វណ្ណៈ កាលដែលពូរៀបការហ្នឹងមានចំនួនប៉ុន្មានគូរ?

អៀម សួន៖ កាលហ្នឹងប្រហែលជា១០ដីង ។

សុខ វណ្ណៈ ចឹងកាលពូធ្វើស្រែនៅជាកសិករហ្នឹងពូមានបាយហូបគ្រប់គ្រាន់ទេ?

អៀម សួន៖ ម៉េចបានហូបគ្រប់គ្រាន់ កាលហ្នឹងហូបតែបបរយកប្រលិតមកលាយ ។

សុខ វណ្ណៈ ចឹងកាលហ្នឹងមានបាយឆ្អែតទេ?

អៀម សួន៖ ម៉េចបានឆ្អែត ។

សុខ វណ្ណៈ ចឹងកាលហ្នឹងមានអ្នកឈឺស្លាប់ដោយសារអត់អាហារទេ?

អៀម សួន៖ មាន ។

សុខ វណ្ណៈ នៅកន្លែងនេះគេហៅតំបន់ប៉ុន្មានកាលសម័យខ្មែរក្រហម?

អៀម សួន៖ មិនដឹងជាតំបន់ប៉ុន្មានទេ គេថាតំបន់៥ ។

សុខ វណ្ណៈ កាលហ្នឹងពីណាជាគណៈស្រុក?

អៀម សួន៖ កាលហ្នឹងមានពីណាទេ...កាលហ្នឹងមាន ឆាត មានឈ្មោះ រៀមមិនដឹងជាពីណាខ្លះទេ ព្រោះគេផ្លាស់ប្តូរគ្នាចាប់អាមួយទៅបាត់ឃើញម្នាក់ទៀតចូលមកចឹងទៅ ។

សុខ វណ្ណៈ ចឹងដល់ពេលចាប' ឆាត ទៅឡើងរៀមវិញ?

អៀម សួន៖ បាទ ។

សុខ វណ្ណៈ ចឹងរៀមហ្នឹងមកពីខាងណាវិញ?

អៀម សួន៖ មិនដឹងជាមកពីខាងណាទេ កាលហ្នឹងមិនហ៊ានមើលមុខគេផង ។

សុខ វណ្ណៈ ចឹងនៅភូមិពូហ្នឹង កាលហ្នឹងមានអ្នកជម្លៀស១៧មេសាមកពីភ្នំពេញទេ?

អៀម សួន៖ មាន ។

សុខ វណ្ណៈ ចឹងពួកហ្នឹងមកមានស្លាប់ច្រើនទេ?

អៀម សួន៖ មកនៅទីនេះក្នុងសម័យនោះមិនសូវមានស្លាប់ទេ នៅភូមិនេះដូចជាស្រួលគ្រាន់ ។

សុខ វណ្ណៈ ចឹងប្រជាជននៅហ្នឹងមិនសូវលំបាកប៉ុន្មានទេ?

អៀម សួន៖ បាទ ។

សុខ វណ្ណៈ ចឹងពូរស់នៅក្នុងភូមិហ្នឹងចំនួនបីឆ្នាំហ្នឹង ពូមានដឹងថាគេយកមនុស្សទៅសម្លាប់មានទេ?

អៀម សួន៖ កាលហ្នឹងបានដឹងដែរ កាលហ្នឹងយកទៅម៉ាកគោកខ្មោចធំមែនោះ ត្រូវជាបងប្អូនខ្ញុំដែរ បងប្អូនជីដូនមួយប៉ុន្មាននាក់ មានអីទៀត ។

សុខ វណ្ណៈ នៅហ្នឹងមានគុកសន្តិសុខអីដែរ?

អៀម សួន៖ បាទ!មិនមានទេ បើចាប់យកទៅមានដាក់នៅថ្មពួកឯណោះ ។

សុខ វណ្ណៈ ចឹងភូមិហ្នឹងមានតាំងពីជំនាន់ដើមមក មិនមែនកើតភូមិនៅសម័យក្រោយនេះទេ?

អៀម សួង៖ បាទ! ភូមិនេះមានតាំងពីកំណើតដូនតាមកហើយ ខ្ញុំកើតមកមានភូមិ ម្ដាយខ្ញុំកើតមកគាត់ ថាមានភូមិតាំងពីណាពីណើមកហើយ ។

សុខ វណ្ណៈ ចឹងភូមិនេះមានរាប់រយឆ្នាំមកហើយ?

អៀម សួង៖ បាទ! មានតាំងពីយូរណាស់មកហើយ មិនដឹងជាយូរប៉ុណ្ណាទេ កើតមកក៏ឃើញភូមិហ្នឹងតែម្ដង ។

សុខ វណ្ណៈ ចឹងព្រៃឈើមិនសូវមានប៉ុន្មានទេ?

អៀម សួង៖ បាទ!មិនសូវមានប៉ុន្មានទេ ស្រុកនេះមានឈើតាមស្រែបន្តិចបន្តួចហ្នឹងចឹងឯង ។

សុខ វណ្ណៈ ចឹងដល់ពេលចប់សម័យបីឆ្នាំ យួនចូលមកពូទៅនៅណាវិញ?

អៀម សួង៖ ខ្ញុំនៅទីនេះឯង ។

សុខ វណ្ណៈ ចឹងពូរស់នៅក្នុងភូមិហ្នឹង ។

អៀម សួង៖ កាលហ្នឹងគេឲ្យធ្វើមេក្រុមកាលសម័យយួន កាលហ្នឹងយ៉ាប់ណាស់មេក្រុម ។

សុខ វណ្ណៈ ចឹងធ្វើមេក្រុមខ្មែរក្រហមចោទថាបានចូលដៃជាមួយខាងនេះ?

អៀម សួង៖ ចឹងហើយ កាលហ្នឹងចេះតែគេចខ្លួនចឹងទៅ ខ្មែរក្រហមឡើងមកទាររកអង្ករកម្ទេចមេក្រុម យួនមកក៏រកមេក្រុម កាំណាស់សម័យហ្នឹង ។

សុខ វណ្ណៈ ចឹងមកសួរថាយ៉ាងម៉េចខ្លះទៅ?

អៀម សួង៖ ទេ មកសួរថាដឹកកំណែនទៅណា កាលនោះកំណែនយួនដឹកទៅថ្នល់ដាច់ ។

សុខ វណ្ណៈ ចឹងកាលឆ្នាំ១៩៧៩-៨១-៨២ហ្នឹងនៅហ្នឹងមានសង្គ្រាមខ្លាំងហើយ?

អៀម សួង៖ បាទ ។

សុខ វណ្ណៈ ចឹងប្រជាជននៅហ្នឹងធ្វើយ៉ាងម៉េចទៅ?

អៀម សួង៖ កាលហ្នឹងចេអតែរត់គេចខ្លួនទៅ "ត្រង់សេ"មានគ្រប់ផ្ទះ ផ្ទះមួយមានត្រង់សេមួយតែវា មិនសូវអីដែលវៃប្រាំវ១ទៅប្រុច ។

សុខ វណ្ណៈ ចឹងពេលដែលវៃចូលដល់ក្នុងភូមិមានដុតផ្ទះអីទេ?

អៀម សួង៖ អត់មានទេ បើប៉ារាឡើងមកបានដុត ។

សុខ វណ្ណៈ ចឹងនៅពេលបាញ់គ្នាចឹង ខាងខ្មែរក្រហមចាញ់រត់ទៅ ពេលវៀតណាមចូលដល់ក្នុងភូមិជួបប្រជាជនធ្វើយ៉ាងម៉េចទៅ?

អៀម សួង៖ យួនមិនបានថា អីទេ ព្រោះជាកន្លែងតំបន់ខ្លាំងមិនដឹងជាធ្វើយ៉ាងម៉េច ។

សុខ វណ្ណៈ ចឹងប្រជាជនមានគ្រោះថ្នាក់ទេ?

អៀម សួនៈ មានគ្រោះថ្នាក់ខ្លះដែរ ។

សុខ វណ្ណៈ ចឹងរស់នៅកន្លែងហ្នឹងដូចជារងគ្រាប់ហើយ?

អៀម សួនៈ បាទ!វាចឹងហើយ ។

សុខ វណ្ណៈ ចឹងប្រជាជនហ៊ានទៅធ្វើស្រែឆ្ងាយៗទេ?

អៀម សួនៈ បាត!ចេះតែទៅៗ យើងធ្វើស្រែហើយ មើលទៅសភាពយ៉ាប់ក៏មិនហ៊ានទៅ កាលនោះ វាពិបាកណាស់ ។

សុខ វណ្ណៈ ចឹងកាលពូធ្វើប្រធានក្រុមដល់ឆ្នាំ៨៣-៨៤-៨៥ហ្នឹងពូមានធ្វើអីទៀតដែរ?

អៀម សួនៈ មិនបានធ្វើអីទេ ។

សុខ វណ្ណៈ ចឹងមានបានចូលធ្វើខ្មែរក្រហមដែរ?

អៀម សួនៈ មិនដែលបានចូលធ្វើខ្មែរក្រហមទេ ។

សុខ វណ្ណៈ ចឹងប៉ារា?

អៀម សួនៈ មិនបានធ្វើទេ ។

សុខ វណ្ណៈ ចឹងពូជាប្រជាជនធម្មតាទេ?

អៀម សួនៈ បាទ ។

សុខ វណ្ណៈ ចឹងកាលសម័យសង្គ្រាមពូរត់លូនជាមួយទ័ពរហូតទៅ?

អៀម សួនៈ បាទ!ខ្ញុំគេចវៀសចឹងទៅ គេចូលមកក៏ពួនទៅ បើគេវ៉ៃខ្លាំងរត់ចូលត្រង់សេទៅ ។

សុខ វណ្ណៈ ចឹងពូនៅហ្នឹងមានដឹងថាខាងទាហានខ្មែរក្រហមចាប់បានទាហានយួនធ្វើយ៉ាងម៉េចទៅ?

អៀម សួនៈ ខ្មែរក្រហមចាប់បានទាហានយួនកាលនោះមិនដឹងជាធ្វើយ៉ាងម៉េចទេ ។

សុខ វណ្ណៈ ចឹងនៅពេលដែលទាហានយួនចាប់បានទាហានខ្មែរក្រហមមានដឹងថាធ្វើយ៉ាងម៉េចទេ?

អៀម សួនៈ ទេ មិនបានដឹងទេ ។

សុខ វណ្ណៈ ចឹងពូនៅហ្នឹងមានដឹងថា នៅពេលវ៉ៃគ្នាមួយគ្រាវៗមានមនុស្សស្លាប់ទេ?

អៀម សួនៈ មានស្លាប់ដែរ ។

សុខ វណ្ណៈ មានស្លាប់គេយកទៅកប់?

អៀម សួនៈ បាទ!កាលនោះទាហានយួនឡើងរថក្រោះមកឡើងវ៉ៃជាមួយកងពលនោះមានស្លាប់ តែត្រូវគេដឹកយកទៅអស់ហើយ ឯងប្រជាជនមានដឹងទេ ។

សុខ វណ្ណៈ ចឹងតែស្លាប់គេយកទៅអស់?

អៀម សួង៖ បាទ! តែស្លាប់គេយកទៅអស់ហើយ ។

សុខ វណ្ណៈ ចឹងនៅហ្នឹងវាចឹងនៅពេលបាញ់អាចឃើញគ្នាទៅវិញទៅមក?

អៀម សួង៖ បាទ! ឃើញគ្នា ។

សុខ វណ្ណៈ កាលហ្នឹងមានកាំភ្លើងធំទេ?

អៀម សួង៖ កាំភ្លើងកាលសម័យនោះមានគ្រប់ធុនហើយ មានទាំងអា១០០លីនៅជាប់លើរថក្រោះ ខាងខ្មែរក្រហមមានតែ“ បេពួក៦២មានអាហុក” ។

សុខ វណ្ណៈ ចឹងមានកាណុងធំសម្រាប់ប្រចាំការ?

អៀម សួង៖ កាណុងធំមានតែខាងយួនហ្នឹងឯង ។

សុខ វណ្ណៈ ចឹងកំលាំងខាងខ្មែរក្រហមកាលហ្នឹងមានច្រើនទេ?

អៀម សួង៖ មានច្រើនណាស់ ។

សុខ វណ្ណៈ ចឹងថ្មីត្បិតតែពូមិនចូលជាខ្មែរក្រហមជាប៉ារា តែពូមានបានដឹងមានកំលាំងខាងប៉ារាហ្នឹង ចាប់តាំងពីឆ្នាំណាមកដែរ?

អៀម សួង៖ ខ្ញុំមិនដែលបានចំណាំអារឿងហ្នឹងទេ មិនដឹងជាកាលណា ប្រហែលជាឆ្នាំ៨១-៨២ហ្នឹង ឯង ។

សុខ វណ្ណៈ ចឹងមកដល់រាល់ថ្ងៃហ្នឹងពូប្រកបមុខរបរអីដែរ?

អៀម សួង៖ ខ្ញុំធ្វើស្រែបន្តិចៗ ហ្នឹង ។

សុខ វណ្ណៈ ចឹងធ្វើបានច្រើនទេ?

អៀម សួង៖ មិនបានច្រើនទេ ចេះតែចែកកូនបណ្តើរៗ ទៅ ។

សុខ វណ្ណៈ ចឹងពូគិតថាកាលសម័យមុនហ្នឹងសម័យឥឡូវការរកស៊ីមានភាពងាយស្រួលឬមួយយ៉ាង ម៉េចដែរ?

អៀម សួង៖ កាលសម័យសង្រ្គាមការធ្វើស្រែមានភ្ញាក់ផ្អើលខ្លះចឹងឯង កាលតឹងទៅក៏ផ្អាកទៅ ។

សុខ វណ្ណៈ ចឹងកាលហ្នឹងលំបាកឬមួយស្រួល?

អៀម សួង៖ លំបាកណាស់ កាលសម័យហ្នឹង ។

សុខ វណ្ណៈ ចឹងមកដល់បច្ចុប្បន្ន?

អៀម សួង៖ ស្រួលសព្វថ្ងៃចង់ទៅណាក៏បាន ។

សុខ វណ្ណៈ ចឹងនៅទីនេះភូមិនេះមានវត្តប៉ុន្មានទៅ?

អៀម សួង៖ នៅទីនេះមិនមានវត្តទេ មានតែនៅផ្សាំ ។

សុខ វណ្ណៈ ចឹងពីដើមមកមានវត្តទេ កាលពីសង្គមចាស់?

អៀម សួងៈ ពីដើមមកភូមិនេះចេះឯង ។

សុខ វណ្ណៈ ចឹងអត់មានវត្តវ៉ាទេ?

អៀម សួងៈ បាទ! ភូមិនេះមានប៉ុន្មានជំនាន់មកហើយ ខ្ញុំកើតមកមិនទាន់ទេ ។

សុខ វណ្ណៈ ចឹងកន្លងមកពូមានដែលតាមដានតុលាកាខ្មែរក្រហមទេ?

អៀម សួងៈ ខ្ញុំមិនដែលបានស្តាប់ទេ ។

សុខ វណ្ណៈ ចឹងកាលហ្នឹងមានស្គាល់ឌុចទេ?

អៀម សួងៈ តា ឌុចឮតែឈ្មោះគេនិយាយតែមិនដែលឃើញរូប ។

សុខ វណ្ណៈ ចឹងតាឌុចមកនៅភូមិផ្គាំនេះពូមិនដែលស្គាល់គាត់ទេ?

អៀម សួងៈ ទេ មិនដែលទេ គេថាតា ឌុចនេះមកនៅភូមិផ្គាំនេះ តែឮតែថាមិនដឹងជារូបយ៉ាងណា ខ្ញុំនៅភូមិនេះមិនដែលបានស្គាល់ដែរ ។

សុខ វណ្ណៈ បាទ ។

អៀម សួងៈ ខ្ញុំមិនដែលបានស្គាល់ទេ ឮតែឈ្មោះ ។

សុខ វណ្ណៈ ចឹងពូមានបានដឹងថា សព្វថ្ងៃមានតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមពូមានដឹងទេ?

អៀម សួងៈ ឮគេថាមានតុលាការសម្រាប់កាត់ទោស ។

សុខ វណ្ណៈ ចឹងពូមានដឹងថាពីណាខ្លះដែលជាប់ឃុំ?

អៀម សួងៈ ខ្ញុំមិនបានដឹងទេ រឿងហ្នឹង ។

សុខ វណ្ណៈ ចឹងខ្ញុំប្រាប់ពូថា តា ឌុចត្រូវបានតុលាការកាត់សេចក្តីហើយ តែនៅមានបណ្តឹងឧទ្ធរណ៍ ចឹងមិនទាន់ដឹងថា គាត់ត្រូវជាប់ទោសពិតប្រាកដប៉ុន្មានឆ្នាំទេ?

អៀម សួងៈ បាទ ។

សុខ វណ្ណៈ មិនដឹងថាជាប់ទោសឬរួចទោសយ៉ាងនោះ កាលមុនតុលាការកាត់ឲ្យជាប់ទោស៣៥ឆ្នាំ ។

អៀម សួងៈ បាទ ។

សុខ វណ្ណៈ តែក្រោយមកតុលាការគិតឃើញថា គាត់ជាប់ទោសនៅតុលាការយោធាដោយមិនបានជម្រះក្តីគាត់ជាច្រើនឆ្នាំ ដូចនេះតុលាការទូទាត់ទៅ ឌុចត្រូវជាប់ទោសតែ១៩ឆ្នាំទៀតទេ ។

អៀម សួងៈ បាទ ។

សុខ វណ្ណៈ ហើយតា ឌុចអតីតជាប្រធានគុកទួលស្លែង ។

អៀម សួង៖ បាទ ។

សុខ វណ្ណៈ ដែលធ្វើឲ្យមនុស្សជាងមួយម៉ឺននាក់នៅទួលស្លែងហ្នឹងស្លាប់ ។

អៀម សួង៖ បាទ ។

សុខ វណ្ណៈ អ្នកដែលជាប់ទោសនៅទួលស្លែងគាត់ជាអ្នកចារឈ្មោះបញ្ជូនទៅឲ្យកងការពារសម្លាប់ ។

អៀម សួង៖ បាទ ។

សុខ វណ្ណៈ ចឹងមានអ្នកទោសនៅទួលស្លែងប្រហែលជា១០បានរួចពីការសម្លាប់ ។

អៀម សួង៖ បាទ ។

សុខ វណ្ណៈ ចឹងក្រៅពីហ្នឹងស្លាប់ទាំងអស់ ។

អៀម សួង៖ បាទ ។

សុខ វណ្ណៈ នៅសម័យហ្នឹងទោះបីគ្រូវជាគ្រូរបស់គាត់ដែលជាប់ទោសនៅទួលស្លែងហ្នឹងក៏គាត់មិនអាចជួយបានដែរ ។

អៀម សួង៖ បាទ ។

សុខ វណ្ណៈ ចឹងអង្គការសម្រេចថាសម្លាប់គឺត្រូវតែសម្លាប់ ។

អៀម សួង៖ បាទ ។

សុខ វណ្ណៈ ទោះបីជាគ្រូដែលធ្លាប់បង្រៀនគាត់ក៏ដោយ ។

អៀម សួង៖ បាទ ។

សុខ វណ្ណៈ ចឹងនៅពេលហ្នឹងមិនអាចជួយបានទេ បើអង្គការសម្រេចថាមានទោសគឺមានទោសហើយមិនអាចជួយបានទេ ។

អៀម សួង៖ បាទ ។

សុខ វណ្ណៈ ចឹងកាលហ្នឹងគាត់ជាមនុស្សផ្តាច់ការដែរ ។

អៀម សួង៖ បាទ ។

សុខ វណ្ណៈ ចឹងការងារទាំងអស់ហ្នឹងធ្លាក់បន្ទុកទៅលើគាត់ ចឹងដល់ពេលប្រទេសមានច្បាប់ទំលាប់ទៅគេត្រូវតែកាត់ទោស ។

អៀម សួង៖ បាទ ។

សុខ វណ្ណៈ ទោះបីអ្នកហ្នឹងមានវ័យចំណាស់យ៉ាងណាក៏ដោយ ឲ្យតែនៅមានជីវិត ។

អៀម សួង៖ បាទ ។

សុខ វណ្ណៈ ដូចជាលោកតា អៀង សារី លោកតា នួន ជា គាត់មានជំងឺផងគាត់មានអាយុ៨០ជាង តែតាមផ្លូវច្បាប់គេមិនអាចអនុគ្រោះឲ្យបានទេ។

អៀម សួង: បាទ។

សុខ វណ្ណៈ ចឹងអ្នកដែលធ្វើខុសត្រូវតែទទួលកំហុស គេដាក់ទោសគាត់ដោយសារគាត់ជាមេដឹកនាំធំ ដែលធ្វើឲ្យប្រជាជនស្លាប់ជាងមួយលាននាក់។

អៀម សួង: បាទ។

សុខ វណ្ណៈ នៅក្នុងប្រទេសកម្ពុជា។

អៀម សួង: បាទ។

សុខ វណ្ណៈ បើសិនជាយើងប្រៀបធៀបនៅប្រទេសផ្សេង គេមានឧក្រិដ្ឋកម្មចឹងដែរ ឧបមាថាប្រទេសគេមានប្រជាជន៦០លាននាក់ គេស្លាប់៣ទៅ៤លាននាក់ក៏នៅតិចជាងយើងដែរ យើងមានតែ៧លាននាក់ ហើយស្លាប់ជាងមួយលាននាក់មានន័យថាស្លាប់ច្រើន។

អៀម សួង: ស្លាប់ច្រើន។

សុខ វណ្ណៈ ដោយសារតែប្រទេសយើងមានមនុស្សតិចហើយស្លាប់រហូតដលទៅជាងមួយលាននាក់ គឺមានន័យថាអស់ច្រើន។

អៀម សួង: បាទ។

សុខ វណ្ណៈ ចឹងមានន័យថាអ្នកដែលបានកាន់អំណាចហើយធ្វើឲ្យប្រជាជនស្លាប់ច្រើនចឹងគឺត្រូវតែកាត់ទោស។

អៀម សួង: បាទ។

សុខ វណ្ណៈ តែមេដឹកនាំដែលធ្វើឲ្យប្រជាជនស្លាប់តិចតួចវាមិនសូវមានបញ្ហាអីទេ។

អៀម សួង: បាទ។

សុខ វណ្ណៈ តែបើមានមនុស្សស្លាប់ច្រើនរំលោភសិទ្ធមនុស្សច្រើនត្រូវតែកាត់ទោស។

អៀម សួង: បាទ។

សុខ វណ្ណៈ ចឹងពូគិតថាកាត់ទោសហ្នឹងមានសារសំខាន់សម្រាប់ប្រជាជនដែរ?

អៀម សួង: កាត់ទោសនោះវាមានសារសំខាន់ហើយ ព្រោះកាលនោះគេបានធ្វើបាបប្រជាពលរដ្ឋខ្លាំងពេក ធ្វើបាបអ្នកស្លូតត្រង់។

សុខ វណ្ណៈ ចឹងពេលមានតុលាការកាត់ទោសប្រជាជនអស់ចិត្ត?

អៀម សួង: បាន។

សុខ វណ្ណៈ ចឹងសម្រាប់ពូដែលទទួលរងគ្រោះដោយធ្វើការហួសកំលាំងហូបមិនឆ្អែតអីចឹង ដល់មានតុលាការកាត់ទោសចឹង តើពូគិតថាអស់ចិត្តទេ ពូអាចទទួលបានយុត្តិធម៌ទេ?

អៀម សួង: សម័យខ្មែរក្រហមកាលនោះធ្វើបាបប្រជាជនពលរដ្ឋខ្លាំង មិនថាប្រជាជនណាទេ ទីងហ្នឹងសម័យខ្មែរក្រហម បែកបាក់បងប្អូន បងប្អូនជីដូនមួយខ្ញុំងាប់កាលសម័យខ្មែរក្រហម ។

សុខ វណ្ណៈ ចឹងនៅទីនេះប្រជាជនចាស់ថ្មីការហូបចុកកាលសម័យហ្នឹងយ៉ាងម៉េចដែរ?

អៀម សួង: ហូបចុកដូចគ្នា ។

សុខ វណ្ណៈ ចឹងដូចគ្នាមិនមានខុសគ្នាទេ?

អៀម សួង: បាទ!ដូចគ្នា កាលនោះហូបបបរដូចគ្នា ។

សុខ វណ្ណៈ កាលហ្នឹងហូបឆ្អែតខ្លះមិនឆ្អែតខ្លះឬយ៉ាងម៉េច?

អៀម សួង: បាទ!ឆ្អែតខ្លះមិនឆ្អែតខ្លះ កាលណាអង្ករគេដឹកមកមិនទាន់មានខ្វះខាត ។

សុខ វណ្ណៈ ចឹងពូមានអីចង់និយាយបន្ថែមទៀតទេ?

អៀម សួង: អត់មានទេ ។

សុខ វណ្ណៈ ចឹងខ្ញុំអរគុណពូច្រើនហើយ?

អៀម សួង: បាទ ។

**ចប់**